Khmer

International
Labour
Office

# Recommendation concerning HIV and AIDS and the World of Work, 2010 (No. 200)









ILO AIDS
www.ilo.org/aids

# មហាសន្និបាតស្តីពីពលកម្មអន្តរជាតិ

**អនុសាសន៍ ២០០**

## អនុសាសន៍ពាក់ព័ន្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ

មហាសន្និបាតរបស់អង្គការពលកម្មអន្តរជាតិ

បានកោះប្រជុំនៅទីក្រុងហ្សឺណែវ ដោយក្រុមប្រឹក្សាភិបាលរបស់អង្គការពលកម្មអន្តរជាតិ និងបានជួបប្រជុំនៅក្នុងកិច្ចប្រជុំលើកទី ៩៩ កាលពីថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១០ និង

បានកត់សម្គាល់ឃើញថា មេរោគអេដស៍ និងជម្ងឺអេដស៍មានផលប៉ះពាល់ធ្ងន់ធ្ងរមកលើសង្គម និងសេដ្ឋកិច្ច, មកលើពិភពការងារ ទាំងនៅក្នុងវិស័យក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ, មកលើកម្មករនិយោជិត គ្រួសារ និងអ្នកក្រោមបន្ទុករបស់ពួកគេ, មកលើអង្គការវិជ្ជាជីវៈរបស់និយោជក និងរបស់កម្មករនិយោជិត និងមកលើសហគ្រាសសាធារណៈ និង ឯកជន និងអាចធ្វើអន្តរាយដល់ការសម្រេចបាននូវការងារសមរម្យ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង

បានបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃតួនាទីរបស់អង្គការពលកម្មអន្តរជាតិ នៅក្នុងការឆ្លើយតបចំពោះបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ នៅក្នុងពិភពការងារ និងភាពចាំបាច់ ដើម្បីឱ្យអង្គការនេះពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវយុត្តិធម៌សង្គម និងប្រយុទ្ធនឹងការមាក់ងាយ និង ការរើសអើងពាក់ព័ន្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការងារ និងភារកិច្ចរបស់ខ្លួន និង

បានរំឭកឡើងវិញពីសារៈសំខាន់នៃការកាត់បន្ថយសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការសម្រេចឱ្យបាននូវការងារសមរម្យ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព សំដៅកៀងគងឱ្យបានកាន់តែប្រសើរនូវពិភពការងារ សម្រាប់ឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ និង

បានកត់សម្គាល់ឃើញកម្រិតខ្ពស់នៃអសមភាពសង្គម និងសេដ្ឋកិច្ច, កង្វះព័ត៌មាន និងការយល់ដឹង, កង្វះការរក្សាការសម្ងាត់ និងការទទួលបានការព្យាបាលមិនបានគ្រប់គ្រាន់ និងមិនបានខ្ជាប់ខ្ជួន, ការកើនឡើងនូវហានិភ័យនៃការចម្លងមេរោគអេដស៍, អត្រាស្លាប់, ចំនួនកុមារដែលបាត់បង់ឪពុក ឬម្តាយ ឬទាំងពីរ និងចំនួនកម្មករនិយោជិត ដែលធ្វើការងារក្រៅប្រព័ន្ធ និង

បានពិចារណាឃើញថា ភាពក្រីក្រ, អសមភាពសង្គម និងសេដ្ឋកិច្ច និងភាពគ្មានការងារធ្វើ ជាកត្តាធ្វើឱ្យមានការកើនឡើងនូវកង្វះការទទួលការបង្ការ ការព្យាបាល ការថែទាំ និងការគាំទ្រ ដែលជាហេតុធ្វើឱ្យមានការកើនឡើងនូវហានិភ័យនៃការចម្លង និង

បានកត់សម្គាល់ឃើញថា ការមាក់ងាយ, ការរើសអើង និងការគម្រាមកំហែងដោយសារការបាត់បង់ការងារ ដែលទទួលរងដោយបុគ្គលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ឬជម្ងឺអេដស៍ គឺជាឧបសគ្គ ដែលរារាំងមិនឱ្យដឹងពីស្ថានភាពមេរោគអេដស៍របស់បុគ្គលណាម្នាក់ ដែលជាកត្តាបង្កើនភាពងាយរងគ្រោះរបស់កម្មករនិយោជិតចំពោះមេរោគអេដស៍ និងធ្វើឱ្យអន្តរាយដល់សិទ្ធិរបស់ពួកគេ ក្នុងការទទួលបាននូវផលប្រយោជន៍សង្គម និង

បានកត់សម្គាល់ឃើញថា មេរោគអេដស៍ និងជម្ងឺអេដស៍មានផលប៉ះពាល់ធ្ងន់ធ្ងរមកលើក្រុមងាយរងគ្រោះ និងក្រុមដែលប្រឈមនឹងហានិភ័យ និង

បានកត់សម្គាល់ថា មេរោគអេដស៍មានផលប៉ះពាល់មកលើបុរសផង និងស្ត្រីផង បើទោះបីជាស្ត្រី និងក្មេងស្រីប្រឈមនឹងហានិភ័យខ្លាំងជាង និងងាយរងគ្រោះដោយសារការឆ្លងមេរោគអេដស៍ និងទទួលរងផលប៉ះពាល់មិនសមមាត្រដោយសារការឆ្លងរាលដាលមេរោគអេដស៍ បើប្រៀបជាមួយនឹងបុរស ដោយសារតែអសមភាពយេនឌ័រ ហើយថា ការផ្តល់អំណាចដល់ស្ត្រី គឺជាកត្តាគន្លឹះមួយ នៅក្នុងការឆ្លើយតបជាសកលចំពោះមេរោគអេដស៍ និងជំងឺអេដស៍ និង

បានរំឭកឡើងវិញពីសារៈសំខាន់នៃការការពារកម្មករនិយោជិត តាមរយៈកម្មវិធីសុខភាព និងសុវត្ថិភាពការងារ ដែលគ្រប់ជ្រុងជ្រោយ និង

បានរំឭកឡើងវិញពីគុណតម្លៃនៃគោលការណ៍អនុវត្តរបស់អង្គការពលកម្មអន្តរជាតិ ដែលមានឈ្មោះថា *គោលការណ៍អនុវត្តរបស់អង្គការពលកម្មអន្តរជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ និងពិភពការងារ* ឆ្នាំ២០០១ និងភាពចាំបាច់ ដើម្បីពង្រឹងលទ្ធផលរយៈពេលវែងរបស់គោលការណ៍នេះ ដោយសារតែមានព្រំដែនកំណត់ និងគម្លាតនៅក្នុងការអនុវត្តគោលការណ៍នេះ និង

បានកត់សម្គាល់ពីភាពចាំបាច់ ដើម្បីផ្សព្វផ្សាយ និងអនុវត្តអនុសញ្ញាពលកម្មអន្តរជាតិ និងអនុសាសន៍នានា និងឧបករណ៍អន្តរជាតិដទៃទៀត ដែលពាក់ព័ន្ធជាមួយមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ រាប់បញ្ចូលទាំងឧបករណ៍ ដែលទទួលស្គាល់សិទ្ធិ ដើម្បីសម្រេចឱ្យបាននូវបទដ្ឋានសុខភាព និងជីវភាពរស់នៅសមរម្យ ក្នុងកម្រិតខ្ពស់បំផុតដែលអាចសម្រេចបាន និង

បានកត់សម្គាល់ពីតួនាទីដ៏សំខាន់របស់កន្លែងធ្វើការពាក់ព័ន្ធជាមួយនឹងព័ត៌មានអំពី និង ការទទួលបានការបង្ការ ការព្យាបាល ការថែទាំ និងការគាំទ្រ នៅក្នុងការឆ្លើយតបថ្នាក់ជាតិ ចំពោះមេរោគអេដស៍ និងជំងឺអេដស៍ និង

បានបញ្ជាក់ពីភាពចាំបាច់ ដើម្បីបន្ត និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេស នៅក្នុងបរិបទនៃកម្មវិធីរួមគ្នារបស់សហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនានា ដើម្បីឱ្យអនុសាសន៍នេះ

ចូលជាធរមាន និង

បានរំឭកឡើងវិញពីគុណតម្លៃនៃកិច្ចសហប្រតិបត្តិការ នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ជាមួយនឹងស្ថាប័ននានា ដែលធ្វើការងារឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ដូចជា វិស័យសុខាភិបាល ជាដើម និងជាមួយអង្គការ/សមាគមនានា ជាពិសេស អង្គការ/សមាគម ដែលតំណាងឱ្យអ្នករស់នៅជាមួយមេរោគអេដស៍ និង

បានបញ្ជាក់ពីភាពចាំបាច់ ដើម្បីបង្កើតបទដ្ឋានអន្តរជាតិមួយ សម្រាប់ផ្តល់ការណែនាំដល់រដ្ឋាភិបាល និងអង្គការវិជ្ជាជីវៈរបស់និយោជក និង សហជីព នៅក្នុងការកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ នៅគ្រប់កម្រិតទាំងអស់ និង

បានធ្វើការសម្រេចចិត្តអំពីការអនុវត្តន៍តាមសំណើមួយចំនួន ពាក់ព័ន្ធជាមួយនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ និង

បានសម្រេចចិត្តថា សំណើទាំងនេះគួរមានទម្រង់ជាអនុសាសន៍

អនុម័តអនុសាសន៍ខាងក្រោមនេះ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០ ដែលអាចហៅថាអនុសាសន៍ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១០។

## I. **និយមន័យ**

១. សម្រាប់គោលបំណងរបស់អនុសាសន៍នេះ:

(ក) "មេរោគអេដស៍" មានន័យថា វីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ ជាវីរុសដែលធ្វើឱ្យខូចប្រព័ន្ធភាពស៊ាំរបស់មនុស្ស។ គេអាចបង្ការការឆ្លងមេរោគនេះ ដោយវិធានការសមស្រប។

(ខ) "ជំងឺអេដស៍" មានន័យថា ចង្កោមរោគសញ្ញាទាំងឡាយ ដែលកើតឡើងក្រោយពេលដែលប្រព័ន្ធភាពស៊ាំសារពាង្គកាយចុះខ្សោយ ដែលកើតឡើងដោយសារការឆ្លងមេរោគអេដស៍ឈានដល់ដំណាក់កាលធ្ងន់ធ្ងរ ហើយត្រូវបានចាត់ប្រភេទជាជំងឺឱកាសនិយម ឬមហារីកពាក់ព័ន្ធនឹងមេរោគអេដស៍ ឬទាំងពីរ។

(គ) "អ្នករស់នៅជាមួយមេរោគអេដស៍" មានន័យថាជាអ្នកដែលឆ្លងមេរោគអេដស៍។

(ឃ) "ការមាក់ងាយ" មានន័យថាជាសញ្ញាសង្គម ដែលនៅពេលមានទំនាក់ទំនងជាមួយបុគ្គលណាម្នាក់ ជាធម្មតាធ្វើឱ្យមានការមិនយកចិត្តទុកដាក់ ឬជាឧបសគ្គមួយ ដែលរារាំងមិនឱ្យអ្នកផ្ទុក ឬរងផលប៉ះពាល់ដោយសារមេរោគអេដស៍ មិនអាចរីករាយនឹងជីវិតក្នុងសង្គមរបស់ខ្លួនឱ្យបានពេញលេញបាន។

(ង) "ការរើសអើង" មានន័យថា ជាការញែកដោយឡែក ការផាត់ចេញ ឬចំណង់ចំណូលចិត្តដែលមានផលប៉ះពាល់ ធ្វើឱ្យមោឃភាព ឬធ្វើឱ្យអន្តរាយដល់សមភាពនៃឱកាស ឬការប្រតិបត្តិ នៅក្នុងការងារ ឬមុខរបរ

ដូចដែលបានលើកឡើងនៅក្នុងអនុសញ្ញាស្តីពីការរើសអើង (នៅក្នុងការងារ និងមុខរបរ) ឆ្នាំ ១៩៥៨ និង អនុសាសន៍ ឆ្នាំ ១៩៥៨។

(ច) "អ្នករងផលប៉ះពាល់" មានន័យថា អ្នកដែលមានជីវិតផ្លាស់ប្តូរដោយសារមេរោគអេដស៍ ឬជំងឺអេដស៍ ដោយសារតែផលប៉ះពាល់ទូលំទូលាយនៃការឆ្លងរាលដាលមេរោគនេះ។

(ឆ) "ការសម្របសមហេតុផល" មានន័យថាជាការផ្លាស់ប្តូរ ឬការកែសម្រួលការងារ ឬកន្លែងធ្វើការ ដែលអាចធ្វើទៅបានយ៉ាងសមហេតុសមផល និងដែលអាចផ្តល់លទ្ធភាពឱ្យអ្នករស់នៅជាមួយមេរោគអេដស៍ ឬជំងឺអេដស៍ទទួលបាន ឬចូលរួម ឬរីកចម្រើន នៅក្នុងការងារ។

(ជ) "ភាពងាយរងគ្រោះ" មានន័យថាឱកាសមិនស្មើគ្នា, ការផាត់ចេញពីសង្គម, ការគ្មានការងារធ្វើ ឬការងារលំបាកខ្លាំង ដែលកើតឡើងដោយសារកត្តាសង្គម, វប្បធម៌, នយោបាយ និងសេដ្ឋកិច្ច ដែលធ្វើឱ្យមនុស្សម្នាក់កាន់តែងាយឆ្លងមេរោគអេដស៍ និងកើតជំងឺអេដស៍។

(ឈ) "កន្លែងធ្វើការ" គឺជាកន្លែងទាំងឡាយណា ដែលកម្មករនិយោជិតធ្វើសកម្មភាពរបស់ពួកគេ។

(ញ) "កម្មករនិយោជិត" សំដៅលើបុគ្គលទាំងឡាយណា ដែលធ្វើការងារក្រោមទម្រង់ ឬការរៀបចំអ្វីមួយ។

## II. វិសាលភាព

២. អនុសាសន៍នេះគ្របដណ្តប់លើ:

(ក) គ្រប់កម្មករនិយោជិតទាំងអស់ ដែលធ្វើការងារក្រោមទម្រង់ ឬការរៀបចំទាំងអស់ និងនៅគ្រប់កន្លែងធ្វើការទាំងអស់ ដូចជា:

(i) អ្នកដែលកំពុងធ្វើការងារ ឬប្រកបមុខរបរអ្វីមួយ

(ii) អ្នកដែលកំពុងទទួលការបណ្តុះបណ្តាល ដូចជា អ្នកហាត់ធ្វើការងារ និងកូនជាង ជាដើម

(iii) អ្នកស្ម័គ្រចិត្ត

(iv) អ្នកស្វែងរកការងារធ្វើ និងអ្នកដាក់ពាក្យសុំធ្វើការងារ និង

(v) កម្មករនិយោជិត ដែលត្រូវបានគេបញ្ឈប់ពីការងារ និងផ្អាកការងារ

(ខ) គ្រប់វិស័យទាំងអស់នៃសកម្មភាពសេដ្ឋកិច្ច ដូចជា វិស័យឯកជន និងវិស័យសាធារណៈ និងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ

(គ) កងកម្លាំងប្រដាប់អាវុធ និងសេវា ដែលតម្រូវឱ្យពាក់ឯកសណ្ឋាន

## III. គោលការណ៍ទូទៅ

៣. គោលការណ៍ទូទៅខាងក្រោមនេះគួរអនុវត្តចំពោះគ្រប់សកម្មភាពទាំងអស់ ដែលពាក់ព័ន្ធជាមួយនឹងការឆ្លើយតបថ្នាក់ជាតិចំពោះមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពិភពការងារៈ

(ក) ការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ គួរត្រូវបានទទួលស្គាល់ថាបានចូលរួមចំណែកចំពោះការសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងសមភាពយេនឌ័រសម្រាប់មនុស្សគ្រប់រូប រាប់ បញ្ចូលទាំងកម្មករនិយោជិត គ្រួសារ និងអ្នកក្រោមបន្ទុករបស់ពួកគេ

(ខ) មេរោគអេដស៍ និងជំងឺអេដស៍ គួរត្រូវបានគេទទួលស្គាល់ និងចាត់ទុកថាជាបញ្ហានៅកន្លែងធ្វើការ ដែលគួរដាក់បញ្ចូល ទៅក្នុងសមាសធាតុសំខាន់ៗនៃការឆ្លើយតបថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ចំពោះការឆ្លងរាលដាលនៃជំងឺនេះ ដោយមានការចូលរួមពេញលេញពីអង្គការវិជ្ជាជីវៈរបស់និយោជក និងកម្មករនិយោជិត

(គ) ពុំគួរមានការរើសអើង ឬការមាក់ងាយចំពោះកម្មករនិយោជិតឡើយ ជាពិសេស អ្នកស្វែងរកការងារធ្វើ និងបេក្ខជនដាក់ពាក្យសុំធ្វើការ ដោយសារមូលហេតុស្ថានភាពមេរោគអេដស៍ជាក់ស្តែង ឬគ្រាន់តែជាការយល់ឃើញ ឬដោយសារតែពួកគេកាន់សាសនា ឬស្ថិតក្នុងក្រុមមនុស្ស ដែលគេយល់ឃើញថាមានហានិភ័យធំធេង ឬងាយឆ្លងមេរោគអេដស៍

(ឃ) ការបង្ការការចម្លងមេរោគអេដស៍តាមគ្រប់មធ្យោបាយទាំងអស់ គួរចាត់ទុកថាជាអាទិភាពជាមូលដ្ឋានមួយ

(ង) កម្មករនិយោជិត គ្រួសារ និងអ្នកក្រោមបន្ទុករបស់ពួកគេគួរអាចប្រើប្រាស់ និងទទួលបានប្រយោជន៍ពីការបង្ការ, ការព្យាបាល, ការថែទាំ និងការគាំទ្រ ពាក់ព័ន្ធជាមួយមេរោគអេដស៍ និងជំងឺអេដស៍ ហើយកន្លែងធ្វើការគួរមានតួនាទីសម្របសម្រួលឱ្យពួកគេទទួលបានសេវាទាំងនេះ

(ច) ការចូលរួម និងការពាក់ព័ន្ធរបស់កម្មករនិយោជិត នៅក្នុងការរៀបចំ ការអនុវត្ត និងការវាយតម្លៃកម្មវិធីថ្នាក់ជាតិ និងកម្មវិធីនៅកន្លែងធ្វើការ គួរត្រូវបានទទួលស្គាល់ និងពង្រឹង

(ឆ) កម្មករនិយោជិតគួរទទួលបានប្រយោជន៍ពីកម្មវិធីទាំងនេះ ដើម្បីបង្ការកុំឱ្យមានការចម្លងមេរោគអេដស៍ និងជំងឺឆ្លងដទៃទៀត ដូចជា ជំងឺរបេង ជាដើម នៅកន្លែងធ្វើការ

(ជ) កម្មករនិយោជិត គ្រួសារ និងអ្នកនៅក្រោមបន្ទុករបស់ពួកគេ គួរទទួលបានការការពារភាពជាឯកជនរបស់ពួកគេ ដូចជា ការរក្សាការសម្ងាត់ពាក់ព័ន្ធជាមួយនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាដើម ជាពិសេស ការសម្ងាត់ពាក់ព័ន្ធនឹងស្ថានភាពមេរោគអេដស៍របស់ពួកគេ

(ឈ) ពុំមានកម្មករនិយោជិតណាគួរត្រូវបានគេតម្រូវឱ្យធ្វើតេស្តរកមេរោគអេដស៍ ឬបង្ហាញពីស្ថានភាពមេរោគអេដស៍របស់ពួកគេឡើយ

(ញ) វិធានការ ដើម្បីឆ្លើយតបចំពោះបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពិភពការងារ គួរជាផ្នែកមួយ

នៃគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ជាតិ រួមទាំងគោលនយោបាយ និងកម្មវិធី ពាក់ព័ន្ធនឹងការងារ ការអប់រំ ការការពារសង្គម និងសុខភាពផងដែរ និង

(ង) ការការពារកម្មករនិយោជិត ដែលធ្វើការងារមានការប្រឈមជាពិសេស ទៅនឹងការឆ្លងមេរោគអេដស៍

## IV. គោលនយោបាយ និងកម្មវិធីថ្នាក់ជាតិ

៤. រដ្ឋជាសមាជិកគួរ:

(ក) អនុម័តលើគោលនយោបាយ និងកម្មវិធីជាតិស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ និងអំពីសុខភាព និងសុវត្ថិភាពការងារ នៅក្នុងករណីមិនទាន់មានគោលនយោបាយ និងកម្មវិធីបែបនេះ

(ខ) ដាក់បញ្ចូលគោលនយោបាយ និងកម្មវិធីជាតិស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ ទៅក្នុងផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដូចជា យុទ្ធសាស្ត្រធានានូវការងារសមរម្យ យុទ្ធសាស្ត្រធានានិរន្តរភាពសហគ្រាស និងយុទ្ធសាស្ត្របង្កើតចំណូល ជាដើម ទៅតាមការសមស្រប

៥. នៅក្នុងការបង្កើតគោលនយោបាយ និងកម្មវិធីជាតិទាំងនេះ អាជ្ញាធរមានសមត្ថកិច្ចគួរពិចារណាលើគោលការណ៍អនុវត្តរបស់អង្គការពលកម្មអន្តរជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ២០១០ និងគោលការណ៍ដែលត្រូវបានកែសម្រួលជាបន្តបន្ទាប់, ឧបករណ៍ពាក់ព័ន្ធផ្សេងទៀតរបស់អង្គការពលកម្មអន្តរជាតិ និងគោលការណ៍ណែនាំអន្តរជាតិដទៃទៀត ដែលត្រូវបានអនុម័តសម្រាប់ការងារនេះ

៦. គោលនយោបាយ និងកម្មវិធីជាតិទាំងនេះគួរត្រូវបានបង្កើតឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ដោយធ្វើការពិគ្រោះយោបល់ជាមួយអង្គការវិជ្ជាជីវៈរបស់និយោជក និងកម្មករនិយោជិត ដែលមានភាពជាតំណាងខ្ពស់បំផុត និងជាមួយអង្គការ ដែលតំណាងឱ្យអ្នករស់នៅជាមួយមេរោគអេដស៍ ដោយធ្វើការពិចារណាលើទស្សនវិស័យរបស់វិស័យដែលពាក់ព័ន្ធនានា ជាពិសេស វិស័យសុខាភិបាល

៧. នៅក្នុងការបង្កើតគោលនយោបាយ និងកម្មវិធីជាតិទាំងនេះ អាជ្ញាធរមានសមត្ថកិច្ចគួរពិចារណាលើតួនាទីរបស់កន្លែងធ្វើការ នៅក្នុងការបង្ការ ការព្យាបាល ការថែទាំ និងការគាំទ្រ ដូចជា ធ្វើការផ្សព្វផ្សាយពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត ដោយសហការជាមួយនឹងសហគមន៍មូលដ្ឋាន ជាដើម

៨. រដ្ឋជាសមាជិកត្រូវឆ្លៀតគ្រប់ឱកាសទាំងអស់ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីគោលនយោបាយ និងកម្មវិធីរបស់ខ្លួនអំពីមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ តាមរយៈអង្គការវិជ្ជាជីវៈរបស់និយោជក និងរបស់កម្មករនិយោជិត, ស្ថាប័នធ្វើការងារផ្នែកមេរោគអេដស៍ និងជំងឺអេដស៍ ដែលពាក់ព័ន្ធ និងច្រកផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

៩. រដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយនឹងអង្គការវិជ្ជាជីវៈរបស់និយោជក និងរបស់កម្មករនិយោជិត ដែលមានភាពជាតំណាងខ្ពស់ជាងគេ គួរធ្វើការពិចារណាផ្តល់ការការពារដោយស្មើភាពគ្នា ដូចដែលបានចែងនៅក្នុង អនុសញ្ញាស្តីពីការរើសអើង (ក្នុងការងារ និងមុខរបរ) ឆ្នាំ ១៩៥៨ ដើម្បីការពារកុំឱ្យមានការរើសអើង ដោយសារស្ថានភាពមេរោគអេដស៍ជាក់ស្តែង ឬដែលគ្រាន់តែយល់ឃើញ។

១០. ស្ថានភាពមេរោគអេដស៍ជាក់ស្តែង ឬដែលគ្រាន់តែយល់ឃើញ មិនគួរជាមូលដ្ឋាននៃការរើសអើង ដែលរារាំងមិនឱ្យមានការជ្រើសរើស ឬការបន្តធ្វើការងារ ឬការទទួលបានឱកាសស្មើភាពគ្នា ស្របជាមួយនឹងប្បញ្ញត្តិ ដែលមានចែងនៅក្នុង អនុសញ្ញាស្តីពីការរើសអើង (ក្នុងការងារ និងមុខរបរ) ឆ្នាំ ១៩៥៨។

១១. ស្ថានភាពមេរោគអេដស៍ជាក់ស្តែង ឬដែលគ្រាន់តែយល់ឃើញ មិនគួរជាមូលហេតុនៃការបញ្ឈប់ពីការងារឡើយ។ អវត្តមានជាបណ្តោះអាសន្ន ដោយសារតែមានជំងឺ ឬមានកាតព្វកិច្ចផ្តល់ការថែទាំដល់អ្នកមានមេរោគអេដស៍ ឬជំងឺអេដស៍ គួរទទួលបានការប្រតិបត្តិដូចគ្នានឹងអវត្តមានពីការងារ ដោយសារតែមូលហេតុសុខភាពដទៃទៀត ស្របទៅតាមអនុសញ្ញាស្តីពីការបញ្ឈប់ពីការងារ ឆ្នាំ ១៩៨២។

១២. នៅពេលដែលវិធានការដែលមានស្រាប់ សម្រាប់ប្រឆាំងនឹងការរើសអើងនៅកន្លែងធ្វើការ នៅមិនទាន់គ្រប់គ្រាន់ដើម្បីផ្តល់ការការពារប្រកបដោយប្រសិទ្ធភាពពីការរើសអើង ដែលពាក់ព័ន្ធជាមួយមេរោគអេដស៍ និងជំងឺអេដស៍ រដ្ឋជាសមាជិកគួរអនុវត្តវិធានការទាំងនេះ ឬដាក់ឱ្យអនុវត្តនូវវិធានការថ្មីៗ និងធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

១៣. បុគ្គល ដែលមានជំងឺពាក់ព័ន្ធជាមួយមេរោគអេដស៍ មិនគួរត្រូវបានគេបដិសេធលទ្ធភាពបន្តការងាររបស់ខ្លួនឡើយ ដោយផ្តល់នូវកែសម្រួលការងារឱ្យបានសមស្រប ក្នុងករណីដែលចាំបាច់ សម្រាប់រយៈពេលដែលបុគ្គលទាំងនោះមានសុខភាពសមស្រប ដើម្បីធ្វើការងារទាំងនេះបាន។ គួរលើកទឹកចិត្តឱ្យមានការចាត់វិធានការនានា ដើម្បីរកការងារផ្សេងឱ្យពួកគេធ្វើ ដែលស្របទៅតាមសមត្ថភាពរបស់ពួកគេ ដើម្បីស្វែងរកការងារផ្សេងទៀត តាមរយៈការបណ្តុះបណ្តាល ឬសម្របសម្រួលឱ្យពួកគេវិលមកធ្វើការងាររបស់ពួកគេវិញ ស្របទៅតាមឧបករណ៍ពាក់ព័ន្ធរបស់អង្គការពលកម្មអន្តរជាតិ និងអង្គការសហប្រជាជាតិ។

១៤. វិធានការនានា គួរត្រូវបានអនុវត្តនៅក្នុង ឬតាមរយៈកន្លែងធ្វើការ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ និងកាត់បន្ថយផលប៉ះពាល់របស់មេរោគនេះ តាមរយៈ :

(ក) ធានាឱ្យមានការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

(ខ) ធានាឱ្យមានសម្ធភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី

(គ) ធានាឱ្យមានសកម្មភាព ដើម្បីបង្ការ និងហាមឃាត់មិនឱ្យមានអំពើហិង្សា និងការបៀតបៀន នៅកន្លែងធ្វើការ

(ឃ) លើកកម្ពស់ឱ្យមានការចូលរួមឱ្យបានសកម្មពីស្ត្រី និងបុរស នៅក្នុងការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍

(ង) លើកកម្ពស់ឱ្យមានការចូលរួម និងផ្តល់ភាពអង់អាចដល់កម្មករនិយោជិតទាំងអស់ ដោយមិនគិតពីចំណង់ចំណូលចិត្តក្នុងការរួមភេទរបស់ពួកគេ និងថាតើពួកគេស្ថិតនៅក្នុងក្រុមងាយរងគ្រោះ ឬអត់

(ច) ផ្សព្វផ្សាយឱ្យមានការការពារសុខភាពផ្លូវភេទ និងបន្តពូជ និងសិទ្ធិផ្លូវភេទ និងបន្តពូជរបស់ស្ត្រី និងបុរស និង

(ឆ) ធានាឱ្យមានការរក្សាការសម្ងាត់ប្រកបដោយប្រសិទ្ធភាពនូវទិន្នន័យផ្ទាល់ខ្លួន រួមទាំង ទិន្នន័យសុខភាព

## *ការបង្ការ*

១៥. យុទ្ធសាស្ត្របង្ការ គួរសម្របទៅតាមស្ថានភាពនៅក្នុងប្រទេស និងប្រភេទកន្លែងធ្វើការ ហើយត្រូវធ្វើការពិចារណាអំពីបញ្ហាយេនឌ័រ សង្គម និងសេដ្ឋកិច្ច

១៦. កម្មវិធីបង្ការគួរធានា:

(ក) ថាមានព័ត៌មានសុក្រឹត បច្ចុប្បន្នភាព ពាក់ព័ន្ធ និងទាន់ពេលវេលា ដែលអាចយកមកប្រើប្រាស់បាន សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ហើយព័ត៌មាននេះមានក្នុងទម្រង់ និងភាសា សមស្របទៅតាមវប្បធម៌ តាមរយៈច្រកប្រាស្រ័យទាក់ទងនានា ដែលមាន

(ខ) កម្មវិធីអប់រំគ្រប់ជ្រុងជ្រោយ ដើម្បីជួយស្ត្រី និងបុរសឱ្យយល់ និងកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ តាមគ្រប់របៀបទាំងអស់ ដូចជា ការចម្លងពីម្តាយទៅកូន និងយល់ពីសារៈសំខាន់ៗនៃការផ្លាស់ប្តូរឥរិយាបថ ដែលធ្វើឱ្យងាយឆ្លងមេរោគនេះ

(គ) វិធានការសុខភាព និងសុវត្ថិភាពការងារ ដែលមានប្រសិទ្ធភាព

(ឃ) វិធានការ ដើម្បីលើកទឹកចិត្តកម្មករនិយោជិត ឱ្យដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេ តាមរយៈការប្រឹក្សា និងការធ្វើតេស្តឈាម ដោយស្ម័គ្រចិត្ត

(ង) លទ្ធភាពប្រើប្រាស់ការការពារតាមគ្រប់មធ្យោបាយទាំងអស់ ដូចជា ការធានាឱ្យមានការផ្គត់ផ្គង់ដែលចាំបាច់ជាពិសេសស្រោមអនាម័យបុរស និងស្ត្រី ទៅតាមការសមស្រប, ព័ត៌មានអំពីការប្រើប្រាស់ស្រោម អនាម័យទាំងនេះឱ្យបានត្រឹមត្រូវនិងការមានវិធីបង្ការការឆ្លងរោគក្រោយពេលប្រឈមនឹងភ្នាក់ងារចម្លងជំងឺរួច

(ច) វិធានការ ដែលមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយឥរិយាបថ ដែលមានហានិភ័យខ្ពស់ ដូចជា ឥរិយាបថរបស់

ក្រុមដែលងាយរងគ្រោះជាងគេ ដើម្បីកាត់បន្ថយករណីឆ្លងមេរោគអេដស៍ និង

(ឆ) យុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ ផ្អែកទៅតាមការណែនាំ ដែលចេញផ្សាយដោយអង្គការសុខភាពពិភពលោក (WHO), កម្មវិធីមេរោគអេដស៍/ជំងឺអេដស៍រួមគ្នារបស់សហប្រជាជាតិ (UNAIDS) និងការិយាល័យសហប្រជាជាតិប្រឆាំងនឹងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងគោលការណ៍ណែនាំដែលពាក់ព័ន្ធដទៃទៀត

*ការព្យាបាល និង ការថែទាំ*

១៧. រដ្ឋជាសមាជិកគួរធានាយ៉ាងណាឱ្យគោលនយោបាយ និងកម្មវិធីជាតិអំពីអន្តរាគមន៍សុខភាព នៅកន្លែងធ្វើការរបស់ខ្លួន ត្រូវបានបង្កើតឡើង ដោយមានការពិគ្រោះយោបល់ជាមួយនិយោជក និងកម្មករនិយោជិត និងតំណាងរបស់ពួកគេ និងភ្ជាប់ទំនាក់ទំនងជាមួយនឹងសេវាសុខភាពសាធារណៈ។ គោលនយោបាយ និងកម្មវិធីទាំងនេះគួររៀបចំឱ្យមានជាអន្តរាគមន៍សមស្រប និងមានប្រសិទ្ធភាពឱ្យបានច្រើនបំផុត ដើម្បីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងគ្រប់គ្រងផលប៉ះពាល់របស់មេរោគអេដស៍ និងជំងឺអេដស៍។

១៨. រដ្ឋជាសមាជិកគួរធានាយ៉ាងណាឱ្យកម្មករនិយោជិត ដែលរស់នៅជាមួយមេរោគអេដស៍ និងអ្នកក្រោមបន្ទុករបស់ពួកគេ ទទួលបានប្រយោជន៍ ពីលទ្ធភាពទទួលបានការថែទាំសុខភាពយ៉ាងពេញលេញ មិនថាការថែទាំនេះត្រូវបានផ្តល់ដោយសេវាសុខភាពសាធារណៈ, ប្រព័ន្ធសន្តិសុខសង្គម ឬការធានារ៉ាប់រងឯកជន ឬគម្រោងដទៃទៀត នោះទេ។ សមាជិកគួរធានាផងដែរឱ្យមានការអប់រំ និងការបង្កើនការយល់ដឹងរបស់កម្មករនិយោជិត ដើម្បីសម្រួលឱ្យពួកគេ ទទួលបានសេវាថែទាំសុខភាព។

១៩. គ្រប់បុគ្គលទាំងអស់ ដែលគ្របដណ្តប់ដោយអនុសាសន៍នេះ រាប់បញ្ចូលទាំង កម្មករនិយោជិតដែលរស់នៅជាមួយមេរោគអេដស៍, គ្រួសារ និងអ្នកក្រោមបន្ទុករបស់ពួកគេ គួរមានសិទ្ធិទទួលបានសេវាសុខភាព។ សេវាទាំងនេះគួរផ្តល់ដោយមិនគិតថ្លៃ ឬដោយតម្លៃសមរម្យៈ

(ក) ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម ដោយស្ម័គ្រចិត្ត

(ខ) ការអប់រំ, ព័ត៌មាន និងការគាំទ្រសម្រាប់ការព្យាបាលដោយប្រើប្រាស់ថ្នាំសម្លាប់មេរោគ និងការព្យាបាលឱ្យបានខ្ជាប់ខ្ជួន

(គ) អាហារូបត្ថម្ភត្រឹមត្រូវ ទៅតាមការព្យាបាល

(ឃ) ការព្យាបាលជំងឺឱកាសនិយម និងជំងឺកាមរោគ និងជំងឺពាក់ព័ន្ធនឹងមេរោគអេដស៍ផ្សេងទៀត ជាពិសេសជំងឺរបេង និង

(ង) កម្មវិធីគាំទ្រ និងបង្ការ សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ ដូចជា ការផ្តល់ការគាំទ្រចិត្តសង្គម ជាដើម

២០. មិនគួរមានការរើសអើងចំពោះកម្មករនិយោជិត ឬអ្នកក្រោមបន្ទុករបស់ពួកគេ ដោយសារស្ថានភាពមេរោគអេដស៍ ពិតប្រាកដ ឬគ្រាន់តែជាការយល់ឃើញ នៅពេលដែលពួកគេប្រើប្រាស់ប្រព័ន្ធសន្តិសុខសង្គម និងគម្រោងធានារ៉ាប់រងការងារ ឬពាក់ព័ន្ធនឹងផលប្រយោជន៍ ដែលទទួលបានពីគម្រោងបែបនេះ ដូចជាផលប្រយោជន៍ជាការថែទាំសុខភាព និងពិការភាព និងផលប្រយោជន៍សម្រាប់មរណៈភាព និងអ្នកក្រោមបន្ទុកសពដែលនៅរស់ ជាដើម ។

*ការគាំទ្រ*

២១. កម្មវិធីផ្តល់ការថែទាំ និងគាំទ្រ គួរដាក់បញ្ចូលវិធានការសម្របសមហេតុសមផល សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ ឬជំងឺពាក់ព័ន្ធនឹងមេរោគអេដស៍ នៅកន្លែងធ្វើការ ពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌក្នុងប្រទេស។ ការងារគួរត្រូវបានរៀបចំ តាមរបៀបដែលសម្របទៅតាមលក្ខណៈឆ្លងរាលដាលរបស់មេរោគអេដស៍ និងជំងឺអេដស៍ និងផលរំខាននៃការព្យាបាល ដែលអាចមាន ។

២២. រដ្ឋជាសមាជិកគួរលើកកម្ពស់ឱ្យមានការរក្សាទុកអ្នករស់នៅជាមួយមេរោគអេដស៍ នៅកន្លែងធ្វើការ និងឱ្យមានការជ្រើសរើសអ្នករស់នៅជាមួយមេរោគអេដស៍ឱ្យចូលធ្វើការ ។ រដ្ឋជាសមាជិកគួរពិចារណាពង្រីកការគាំទ្រ ក្នុងកំឡុងពេលមានការងារធ្វើ និងពេលគ្មានការងារធ្វើ រួមទាំងផ្តល់ការគាំទ្រ នៅក្នុងករណីដែលចាំបាច់ត្រូវឱ្យអ្នករស់នៅជាមួយមេរោគអេដស៍ ឬអ្នកទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ឬជំងឺអេដស៍មានឱកាសរកចំណូល ។

២៣. នៅក្នុងករណី ដែលអាចមានទំនាក់ទំនងដោយផ្ទាល់រវាងការងារមួយ និងហានិភ័យនៃការឆ្លងជំងឺ ជំងឺអេដស៍ និងការឆ្លងមេរោគអេដស៍ គួរត្រូវបានទទួលស្គាល់ថាជាជំងឺវិជ្ជាជីវៈ ឬជាគ្រោះថ្នាក់មួយ ទៅតាមនីតិវិធី និងនិយមន័យរបស់ជាតិ និងដោយយោងទៅតាមបញ្ជីអនុសាសន៍ស្តីពីជំងឺវិជ្ជាជីវៈ ឆ្នាំ ២០០២ និងឧបករណ៍ពាក់ព័ន្ធផ្សេងទៀតរបស់អង្គការពលកម្មអន្តរជាតិ ។

*ការធ្វើតេស្ត ភាពឯកជន និង ការរក្សាការសម្ងាត់*

២៤. ការធ្វើតេស្តត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពិតប្រាកដ និងគ្មានការបង្ខិតបង្ខំ ហើយកម្មវិធីធ្វើតេស្តនេះទៀតសោតត្រូវគោរពទៅតាមគោលការណ៍ណែនាំអន្តរជាតិអំពីការរក្សាការសម្ងាត់ ការផ្តល់ប្រឹក្សា និងការយល់ព្រម ។

២៥. មិនគួរមានការតម្រូវឱ្យកម្មករនិយោជិត រាប់បញ្ចូលទាំងពលករចំណាកស្រុក អ្នកស្វែងរកការងារធ្វើ និងបេក្ខជនដាក់ពាក្យសុំធ្វើការ ឱ្យធ្វើតេស្តរកមេរោគអេដស៍ ឬរកមេរោគអេដស៍ក្នុងទម្រង់ផ្សេងទៀត នោះឡើយ ។

២៦. លទ្ធផលនៃការធ្វើតេស្តរកមេរោគអេដស៍គួររក្សាការសម្ងាត់ និងមិនធ្វើឱ្យប៉ះពាល់ដល់ការងារ មុខតំណែង ភាពជាប់លាប់នៃការងារ ឬឱកាសរីកចម្រើននៅក្នុងការងារ ។

២៧. កម្មករនិយោជិត រាប់បញ្ចូលទាំងពលករចំណាកស្រុក អ្នកស្វែងរកការងារធ្វើ និងបេក្ខជនដាក់ពាក្យសុំធ្វើការ មិនគួរត្រូវបានប្រទេសដែលប្រភពដើមរបស់ពួកគេ, ប្រទេសដែលពួកគេឆ្លងកាត់ ឬប្រទេសដែលជាទិសដៅរបស់ពួក គេ តម្រូវឱ្យបង្ហាញព័ត៌មានពាក់ព័ន្ធនឹងមេរោគអេដស៍អំពីពួកគេផ្ទាល់ ឬអំពីអ្នកដទៃនោះឡើយ។ ការទទួលបានព័ត៌មានទាំងនេះ គួរស្ថិតនៅក្រោមវិធានរក្សាការសម្ងាត់ ស្របជាមួយនឹងគោលការណ៍អនុវត្តរបស់អង្គការពលកម្មអន្តរជាតិស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួនរបស់កម្មករនិយោជិត ១៩៩៧ និងបទដ្ឋានអន្តរជាតិស្តីពីការការពារទិន្នន័យ ដែលពាក់ព័ន្ធផ្សេងទៀត។

២៨. ពលករចំណាកស្រុក ឬអ្នកដែលមានគោលបំណងធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើ មិនគួរត្រូវបានប្រទេសដែលប្រភពដើមរបស់ពួកគេ, ប្រទេសដែលពួកគេឆ្លងកាត់ ឬប្រទេសដែលជាទិសដៅរបស់ពួកគេ ហាមឃាត់មិនឱ្យធ្វើចំណាកស្រុក ដោយសារតែស្ថានភាពមេរោគអេដស៍ពិតប្រាកដ ឬដែលគេយល់ឃើញ នោះឡើយ។

២៩. រដ្ឋជាសមាជិកគួរដាក់ឱ្យអនុវត្តនូវនីតិវិធីដោះស្រាយវិវាទងាយស្រួលប្រើប្រាស់ ដែលធានាឱ្យមានដំណោះស្រាយសម្រាប់កម្មករនិយោជិត ដែលទទួលរងការរំលោភបំពានសិទ្ធិខាងលើរបស់ពួកគេ។

*សុខភាព និង សុវត្ថិភាពការងារ*

៣០. បរិយាកាសការងារគួរធានាសុវត្ថិភាព និងសុខភាព ដើម្បីបង្ការការឆ្លងមេរោគអេដស៍ នៅក្នុងកន្លែងធ្វើការ ស្របជាមួយនឹងអនុសញ្ញាស្តីពីសុខភាព និងសុវត្ថិភាពការងារ ១៩៨១ និងអនុសាសន៍ ១៩៨១, ក្របខ័ណ្ឌផ្សព្វផ្សាយពីអនុសញ្ញាស្តីពីសុខភាព និងសុវត្ថិភាពការងារ ២០០៦ និងអនុសាសន៍ ២០០៦ និងឧបករណ៍អន្តរជាតិដែលពាក់ព័ន្ធដទៃទៀត ដូចជាឯកសារណែនាំរួមគ្នារបស់ការិយាល័យពលកម្មអន្តរជាតិ និងអង្គការសុខភាពពិភពលោក ជាដើម។

៣១. វិធានការសុវត្ថិភាព និងសុខភាព ដើម្បីការពារកម្មករនិយោជិតមិនឱ្យប្រឈមនឹងមេរោគអេដស៍ នៅកន្លែងធ្វើការគួរដាក់បញ្ចូលបម្រុងប្រយ័ត្នជាសកល, វិធានការបង្ការគ្រោះថ្នាក់ និងគ្រោះភ័យផ្សេងៗ ដូចជាវិធានការតាមរយៈការរៀបចំ, ការត្រួតពិនិត្យវិស្វកម្ម និងការអនុវត្តការងារ, សម្ភារការពារខ្លួន ទៅតាមការសមស្រប, វិធានការត្រួតពិនិត្យបរិស្ថាន, បម្រុងប្រយ័ត្នក្រោយពេលប្រឈមនឹងមេរោគ និងវិធានការសុវត្ថិភាពដទៃទៀត ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគអេដស៍ និងជំងឺរបេង ជាពិសេស ក្នុងការងារ ដែលប្រឈមនឹងហានិភ័យខ្ពស់ជាងគេ ដូចជា នៅក្នុងវិស័យថែទាំសុខភាព ជាដើម។

៣២. នៅពេលមានលទ្ធផលប្រឈមនឹងការឆ្លងមេរោគអេដស៍ នៅកន្លែងធ្វើការ កម្មករនិយោជិតគួរទទួលបានការ អប់រំ និងការបណ្តុះបណ្តាលអំពីរបៀបចម្លង និងវិធានការបង្ការការប្រឈម និងការចម្លងមេរោគនេះ។ រដ្ឋជាសមាជិក គួរចាត់វិធានការដើម្បីធានាឱ្យមានការបង្ការការធានាសុវត្ថិភាពនិងសុខភាពស្របទៅតាមបទដ្ឋានដែលពាក់ព័ន្ធ។

៣៣.វិធានការលើកកម្ពស់ការយល់ដឹងគួរផ្តោតសំខាន់លើព័ត៌មានដែលថា មេរោគអេដស៍មិនឆ្លងតាមរយៈការប៉ះពាល់រូបរាងកាយធម្មតានោះឡើយ ហើយវត្តមានរបស់អ្នករស់នៅជាមួយមេរោគអេដស៍មិនគួរត្រូវបានគេចាត់ទុកថាជាមុខសញ្ញាគ្រោះភ័យរបស់កន្លែងធ្វើការឡើយ ។

៣៤. សេវាសុខភាពការងារ និងយន្តការនៅកន្លែងធ្វើការ ពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងារ គួរឆ្លើយតបទៅនឹងបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ស្របជាមួយនឹងអនុសញ្ញាស្តីពីសេវាសុខភាពការងារ ១៩៨៥ និងអនុសាសន៍ ១៩៨៥ និង*គោលការណ៍ណែនាំរួមរបស់អង្គការពលកម្មអន្តរជាតិ/អង្គការសុខភាពពិភពលោកស្តីពីសេវាសុខភាព និងមេរោគអេដស៍/ជំងឺអេដស៍ ២០០៥* និងគោលការណ៍ណែនាំ ដែលត្រូវបានកែសម្រួលជាបន្តបន្ទាប់ ក៏ដូចជាឧបករណ៍អន្តរជាតិ ដែលពាក់ព័ន្ធដទៃទៀត ។

*កុមារ និង យុវវ័យ*

៣៥. រដ្ឋជាសមាជិកគួរចាត់វិធានការ ដើម្បីទប់ស្កាត់ពលកម្មកុមារ និងការជួញដូរកុមារ ដែលអាចបន្ទាប់ពីសមាជិកគ្រួសារ ឬអាណាព្យាបាលរបស់ពួកគេស្លាប់ ឬឈឺ ដោយសារមេរោគអេដស៍ និងដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារចំពោះមេរោគអេដស៍ ស្របទៅតាមសេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋាន នៅកន្លែងធ្វើការ ១៩៩៨, អនុសញ្ញាស្តីពីអាយុអប្បបរមា ១៩៧៣ និងអនុសាសន៍ ១៩៧៣, និងអនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ១៩៩៩ និងអនុសាសន៍ ១៩៩៩។ គួរមានការអនុវត្តវិធានការពិសេស ដើម្បីការពារកុមារទាំងនេះពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ ។

៣៦. រដ្ឋជាសមាជិកគួរចាត់វិធានការ ដើម្បីការពារកម្មករនិយោជិតជាយុវវ័យឱ្យរួចផុតពីការឆ្លងមេរោគអេដស៍ និងត្រូវដាក់បញ្ចូលតម្រូវការពិសេសរបស់កុមារ និងយុវវ័យ ទៅក្នុងការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ដែលមាននៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ។ គោលនយោបាយ និងកម្មវិធីទាំងនេះគួរដាក់បញ្ចូលការអប់រំអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ជាពិសេស ការផ្សព្វផ្សាយព័ត៌មានអំពីមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធី និងសេវារកការងារធ្វើឱ្យដល់យុវជន ។

## V. **ការអនុវត្ត**

៣៧. គោលនយោបាយ និងកម្មវិធីជាតិស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ គួរៈ

(ក) ចូលជាធរមាន ដោយមានការពិគ្រោះយោបល់ជាមួយអង្គការវិជ្ជាជីវៈរបស់និយោជក និងកម្មករនិយោជិតដែលមានភាពជាតំណាងខ្ពស់បំផុត និងភាគីដទៃទៀតដែលពាក់ព័ន្ធ ដូចជា អង្គការ/ស្ថាប័នសាធារណៈ និងឯកជន ធ្វើការងារផ្នែកសុខភាពការងារដែលពាក់ព័ន្ធ តាមរយៈមធ្យោបាយមួយ ឬមធ្យោបាយច្រើន

ខាងក្រោមបញ្ចូលគ្នា៖

(i) ច្បាប់ និងលិខិតបទដ្ឋានជាតិ

(ii) អនុសញ្ញារួម

(iii) គោលនយោបាយ និងកម្មវិធីសកម្មភាពថ្នាក់ជាតិ និងរបស់កន្លែងធ្វើការ និង

(iv) យុទ្ធសាស្ត្រតាមវិស័យ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះវិស័យ ដែលមានហានិភ័យខ្ពស់បំផុត សម្រាប់បុគ្គលិក ដែលត្រូវបានគ្របដណ្តប់ដោយអនុសាសន៍នេះ

(ខ) ជម្រុញឱ្យមានការចូលរួមពីអាជ្ញាធរតុលាការ ដែលមានសមត្ថកិច្ចលើបញ្ហាការងារ និងអាជ្ញាធររដ្ឋបាលការងារ នៅក្នុងការរៀបចំផែនការ និងការអនុវត្តគោលនយោបាយ និងកម្មវិធីនានា ហើយគួរមានការរៀបចំការបណ្តុះបណ្តាលសម្រាប់ពួកគេ

(គ) រៀបចំឱ្យមានជាវិធានការ នៅក្នុងច្បាប់ និងលិខិតបទដ្ឋានជាតិ ដើម្បីឆ្លើយតបចំពោះការរំលោភលើភាពជាឯកជន និងការរក្សាការសម្ងាត់ និងការការពារដទៃទៀត ក្រោមអនុសាសន៍នេះ

(ឃ) ធានាឱ្យមានការសហការ និងការសម្របសម្រួល ក្នុងចំណោមអាជ្ញាធរសាធារណៈ និងសេវាសាធារណៈ និងឯកជន ដែលពាក់ព័ន្ធ រួមបញ្ចូលទាំងកម្មវិធីធានារ៉ាប់រង និងផ្តល់ផលប្រយោជន៍ ឬកម្មវិធីដទៃទៀត

(ង) លើកកម្ពស់ និងគាំទ្រឱ្យសហគ្រាសទាំងអស់អនុវត្តតាមគោលនយោបាយ និងកម្មវិធីជាតិ ដូចជា តាមរយៈចង្វាក់នៃការផ្គត់ផ្គង់ និងបណ្តាញចែកចាយរបស់ពួកគេ ដោយមានការចូលរួមពីអង្គការវិជ្ជាជីវៈរបស់និយោជក និងកម្មករនិយោជិត និងធានាយ៉ាងណាឱ្យសហគ្រាស ដែលបំពេញការងារនៅក្នុងតំបន់ផលិតសម្រាប់នាំចេញ អនុវត្តទៅតាមគោលនយោបាយ និងកម្មវិធីជាតិទាំងនេះ

(ច) លើកកម្ពស់ឱ្យមានសំវាទសង្គម (កិច្ចសន្ទនាសង្គម) ដូចជា ការពិគ្រោះយោបល់ និងការចរចា ជាដើម ស្របទៅតាមអនុសញ្ញាស្តីពីការពិគ្រោះយោបល់ត្រីភាគី (បទដ្ឋានពលកម្មអន្តរជាតិ) ១៩៧៦ និងទម្រង់នៃការសហការផ្សេងទៀតក្នុងចំណោមអាជ្ញាធររដ្ឋាភិបាល, និយោជកក្នុងវិស័យសាធារណៈ និងឯកជន និងកម្មករនិយោជិត និងតំណាងរបស់ពួកគេ ដោយធ្វើការពិចារណាលើទស្សនៈរបស់បុគ្គលិកផ្នែកសុខភាពការងារ, អ្នកឯកទេសផ្នែមេរោគអេដស៍ និងជំងឺអេដស៍ និងភាគីដទៃទៀត ដូចជាអង្គការ/សមាគមតំណាងអ្នករស់នៅជាមួយមេរោគអេដស៍, អង្គការអន្តរជាតិ, អង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ និងយន្តការសម្របសម្រួលប្រចាំប្រទេស ជាដើម

(ឆ) ត្រូវបានបង្កើត, អនុវត្ត, ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ស្របទៅតាមការវិវឌ្ឍផ្នែកសង្គម និងវិទ្យាសាស្ត្រចុងក្រោយបំផុត និងទៅតាមតម្រូវការ ដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រ និងវប្បធម៌

(ជ) សម្របសម្រួលជាមួយនឹងគោលនយោបាយ និងកម្មវិធីការងារ, សន្តិសុខសង្គម និងសុខភាព និងគោលនយោបាយ និងកម្មវិធីដទៃទៀត និង

(ឈ) ធានាយ៉ាងណាឱ្យរដ្ឋជាសមាជិករៀបចំមធ្យោបាយសមស្រប ដើម្បីអនុវត្តគោលនយោបាយ និងកម្មវិធីទាំងនេះ ស្របទៅតាមស្ថានភាពក្នុងប្រទេស និងសមត្ថភាពរបស់និយោជក និងកម្មករនិយោជិត

*ការចរចាសង្គម*

៣៨. ការអនុវត្តគោលនយោបាយ និងកម្មវិធីស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ គួរមានមូលដ្ឋានលើការសហការ និងការជឿទុកចិត្តគ្នា រវាងនិយោជក និងកម្មករនិយោជិត និងតំណាងរបស់ពួកគេ និងរដ្ឋាភិបាល ដោយមានការចូលរួមយ៉ាងសកម្មពីអ្នករស់នៅជាមួយមេរោគអេដស៍ នៅកន្លែងធ្វើការរបស់ពួកគេ

៣៩. អង្គការវិជ្ជាជីវៈរបស់និយោជក និងកម្មករនិយោជិត គួរលើកកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ ដូចជាការបង្ការ និងការរើសអើង តាមរយៈការផ្តល់នូវការអប់រំ និងព័ត៌មាន ដល់សមាជិករបស់ខ្លួន។ សកម្មភាពទាំងនេះ គួរពិចារណាអំពីបញ្ហាយេនឌ័រ និងវប្បធម៌។

*ការអប់រំ ការបណ្តុះបណ្តាល ព័ត៌មាន និងការពិគ្រោះយោបល់*

៤០. ការបណ្តុះបណ្តាល ការណែនាំអំពីសុវត្ថិភាព និងការណែនាំចាំបាច់នានា នៅកន្លែងធ្វើការ ពាក់ព័ន្ធនឹងមេរោគ អេដស៍ និងជំងឺអេដស៍ គួរផ្តល់ក្នុងទម្រង់ច្បាស់លាស់ ងាយស្រួលយល់ ដល់កម្មករនិយោជិតទាំងអស់ ជាពិសេសពលករចំណាកស្រុក, កម្មករនិយោជិតដែលទើបចូលថ្មី ឬដែលពុំមានបទពិសោធន៍, កម្មករនិយោជិតក្មេងៗ ឬអ្នកដែលកំពុងបណ្តុះបណ្តាល ដូចជាអ្នកហាត់ធ្វើការ និងកូនជាង ជាដើម។ ការបណ្តុះបណ្តាល និងការណែនាំ គួរពិចារណាអំពីបញ្ហាយេនឌ័រ និងវប្បធម៌ និងសម្របទៅតាមលក្ខណៈរបស់កន្លែងធ្វើការ ដោយធ្វើការពិចារណាអំពីកត្តាហានិភ័យសម្រាប់កន្លែងធ្វើការ។

៤១. ព័ត៌មានវិទ្យាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចបច្ចុប្បន្នភាព និងការអប់រំ និងការបណ្តុះបណ្តាលអំពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងករណីសមស្រប គួរផ្តល់ដល់និយោជក អ្នកគ្រប់គ្រង និងតំណាងកម្មករនិយោជិត ដើម្បីជួយពួកគេនៅក្នុងការអនុវត្តតាមវិធានការសមស្រប នៅក្នុងកន្លែងធ្វើការ។

៤២. កម្មករនិយោជិត រួមទាំង អ្នកហាត់ធ្វើការងារ អ្នកទទួលការបណ្តុះបណ្តាល និងអ្នកស្ម័គ្រចិត្ត គួរទទួលបាននូវព័ត៌មាន បង្កើនការយល់ដឹង និងការបណ្តុះបណ្តាលសមស្របអំពីរបៀបទប់ស្កាត់ការឆ្លងមេរោគអេដស៍នៅក្នុងបរិបទនៃគ្រោះថ្នាក់ និងការសង្គ្រោះបឋមនៅកន្លែងធ្វើការ។ កម្មករនិយោជិត ដែលមានការងារ ធ្វើឱ្យពួកគេប្រឈមនឹងការប៉ះពាល់ឈាមរបស់មនុស្ស ផលិតផលឈាម និងសារធាតុរាវរាងកាយផ្សេងទៀត គួរទទួលបានការបណ្តុះបណ្តាលបន្ថែមពីការបង្ការការប្រឈម,នីតិវិធីកត់ត្រាព័ត៌មានអំពីការប្រឈមនិងបម្រុងប្រយ័ត្នក្រោយពេលប្រឈម

៤៣. កម្មករនិយោជិត និងតំណាងរបស់ពួកគេ គួរមានសិទ្ធិទទួលបានព័ត៌មាន និងត្រូវបានគេពិគ្រោះយោបល់ជាមួយ អំពីវិធានការ ដែលបានរៀបចំ ដើម្បីអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកន្លែងធ្វើការ។ តំណាងកម្មករនិយោជិត និងតំណាងនិយោជកគួរចូលរួម នៅក្នុងការត្រួតពិនិត្យកន្លែងធ្វើការ ដោយអនុលោមទៅតាមការអនុវត្តរបស់ជាតិ។

*សេវាសាធារណៈ*

៤៤. គួរមានការពិនិត្យឡើងវិញ និងពង្រីកបន្ថែមតួនាទីរបស់សេវារដ្ឋបាលការងារ ដូចជា អធិការកិច្ចការងារ និងអាជ្ញាធរតុលាការ ដែលមានសមត្ថកិច្ចលើបញ្ហាការងារ នៅក្នុងការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍។

៤៥. គួរមានការពង្រឹងប្រព័ន្ធសុខាភិបាលសាធារណៈ និងអនុវត្តទៅតាម*គោលការណ៍ណែនាំរួមរបស់អង្គការពលកម្មអន្តរជាតិ/អង្គការសុខភាពពិភពលោកអំពីសេវាសុខភាព និងមេរោគអេដស៍/ជំងឺអេដស៍* ២០០៥ និងគោលការណ៍ណែនាំ ដែលត្រូវបានកែសម្រួលជាបន្តបន្ទាប់ ដើម្បីធានាឱ្យមានការទទួលបានការបង្ការ ការព្យាបាល ការថែទាំ និងការគាំទ្រឱ្យបានកាន់តែទូលំទូលាយ និងកាត់បន្ថយបន្ទុកបន្ថែម ដោយសារមេរោគអេដស៍ និង ជំងឺអេដស៍លើសេវាសាធារណៈ ជាពិសេសលើបុគ្គលិកសុខាភិបាល។

*សហប្រតិបត្តិការអន្តរជាតិ*

៤៦. រដ្ឋជាសមាជិកគួរសហការគ្នា តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី តាមរយៈការចូលរួមនៅក្នុងប្រព័ន្ធពហុភាគី ឬតាមរយៈមធ្យោបាយ ដែលមានប្រសិទ្ធភាពដទៃទៀត ដើម្បីឱ្យអនុសាសន៍នេះចូលជាធរមាន។

៤៧. វិធានការ ដើម្បីធានាឱ្យមានការទទួលបានសេវាបង្ការ ព្យាបាល ថែទាំង និងគាំទ្រ សម្រាប់ពលករចំណាកស្រុក គួរត្រូវបានអនុវត្តដោយប្រទេសដែលប្រភពដើមរបស់ពួកគេ, ប្រទេសដែលពួកគេឆ្លងកាត់ ឬប្រទេសដែលជាទិសដៅរបស់ពួកគេ ហើយគួរមានកិច្ចព្រមព្រៀងរវាងប្រទេសនានា ដែលពាក់ព័ន្ធ នៅពេលដែលសមស្រប។

៤៨. គួរលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាង និងក្នុងចំណោមរដ្ឋជាសមាជិក, ស្ថាប័នជាតិផ្នែក មេរោគ និង ជំងឺអេដស៍ និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ហើយគួរដាក់បញ្ចូលការផ្លោះប្តូរ ដែលមានលក្ខណៈជាប្រព័ន្ធនូវព័ត៌មានអំពីគ្រប់វិធានការទាំងអស់ ដែលត្រូវបានអនុវត្ត ដើម្បីឆ្លើយតបចំពោះការឆ្លងរាលដាលមេរោគអេដស៍។

៤៩. រដ្ឋជាសមាជិក និងអង្គការ/ស្ថាប័នពហុភាគីគួរផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការសម្របសម្រួល និងលើធនធានចាំបាច់នានា ដើម្បីបំពេញទៅតាមតម្រូវការរបស់គ្រប់ប្រទេសទាំងអស់ ជាពិសេស ប្រទេសដែលមានប្រេវ៉ាឡង់ខ្ពស់ នៅក្នុងការបង្កើតយុទ្ធសាស្ត្រ និងកម្មវិធីអន្តរជាតិសម្រាប់ផ្តល់ការបង្ការ ការព្យាបាល ការថែទាំ និង

ការគាំទ្រពាក់ព័ន្ធជាមួយនឹងមេរោគអេដស៍។

៥០. រដ្ឋជាសមាជិក និងអង្គការអន្តរជាតិ គួរព្យាយាមកាត់បន្ថយតម្លៃនៃការផ្ដល់គ្រប់ប្រភេទទាំងអស់ សម្រាប់ការបង្ការ ការព្យាបាល និងការថែទាំជំងឺ ដែលបង្កឡើងដោយមេរោគអេដស៍ ជំងឺឱកាសនិយមផ្សេងទៀត និងជំងឺមហារីក ពាក់ព័ន្ធជាមួយមេរោគអេដស៍។

## VI. **ការបន្តតាមដាន**

៥១. រដ្ឋជាសមាជិកគួរបង្កើតឱ្យមាននូវយន្តការសមស្របមួយ ឬប្រើប្រាស់យន្តការដែលមានស្រាប់ ដើម្បីពិនិត្យតាមដានការអភិវឌ្ឍនានា ពាក់ព័ន្ធជាមួយនឹងគោលនយោបាយជាតិអំពីមេរោគអេដស៍ និងជំងឺអេដស៍ និងពិភពការងារ ក៏ដូចជាដើម្បីផ្ដល់ជាដំបូន្មានអំពីការបង្កើត និងការអនុវត្តគោលនយោបាយនេះ។

៥២. អង្គការវិជ្ជាជីវៈរបស់និយោជក និងកម្មករនិយោជិត ដែលមានភាពជាតំណាងខ្ពស់បំផុត គួរមានតំណាងដោយស្មើភាពគ្នា នៅក្នុងយន្តការពិនិត្យតាមដានវឌ្ឍនភាពរបស់គោលនយោបាយជាតិ។ លើសពីនេះទៅទៀត អង្គការវិជ្ជាជីវៈទាំងនេះគួរត្រូវបានគេពិគ្រោះយោបល់ជាមួយ នៅក្រោមយន្តការនេះ ឱ្យបានញឹកញាប់តាមការចាំបាច់ ដោយធ្វើការពិចារណាលើទស្សនៈរបស់អង្គការ/សមាគមអ្នករស់នៅជាមួយមេរោគអេដស៍ របាយការណ៍របស់អ្នកជំនាញ ឬការសិក្សាបច្ចេកទេសផ្សេងៗ។

៥៣. តាមដែលអាចធ្វើបាន រដ្ឋជាសមាជិកគួរប្រមូលព័ត៌មានលំអិត និងទិន្នន័យស្ថិតិ និងធ្វើការស្រាវជ្រាវអំពីការអភិវឌ្ឍនៅកម្រិតជាតិ និងកម្រិតវិស័យ ពាក់ព័ន្ធជាមួយនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពិភពការងារ ដោយធ្វើការពិចារណាលើរបាយស្ត្រី និងបុរស និងកត្តាដែលពាក់ព័ន្ធដទៃទៀត។

៥៤. បន្ថែមពីលើការរាយការណ៍ ក្រោមមាត្រាទី ១៩ នៃធម្មនុញ្ញរបស់អង្គការពលកម្មអន្តរជាតិ ការពិនិត្យឡើងវិញជាទៀងទាត់លើសកម្មភាព ដែលត្រូវបានអនុវត្តទៅតាមអនុសាសន៍នេះ អាចដាក់បញ្ចូលទៅក្នុងរបាយការណ៍ជាតិ ដែលផ្ញើទៅ UNAIDS និងរបាយការណ៍នានា ដែលស្ថិតនៅក្រោមឧបករណ៍អន្តរជាតិ ដែលពាក់ព័ន្ធ។